# មើលរាសី៨ជាន់

ប្រុសអាយុបាន : ១២,២០,២៨,៣៦,៤៤,៥២ និង ៦០ ឆ្នាំ ។

ស្រីអាយុបាន : ១៤,២២,៣០,៣៨,៤៦ និង ៥៤ ឆ្នាំ ។

១-លោកអ្នកនាងមានអាយុប៉ុណ្ណេះ រាសីឡើងខ្ពស់ណាស់ តាមការពិតសេចក្តីប្រព្រឹត្ត និងព្យាយាមរបស់អាត្មាមនត្រឹមណាវត្ថុធាតុដែលចោមរោមជុំវិញខ្លួនមានរង្វាលប៉ុន្មាន សឹងបានប្រសើរលើសលប់ សេចក្តីសុខកាយសប្បាយចិត្ត លាភផលញាតិមិត្តជិតឆ្ងាយ វិជ្ជាការសិក្សា យសស័ក្តិអំណាច គតិភាពទាំងអម្បាលនេះ សុទ្ធតែមានជោគជ័យប្រកបទៅដោយការលូតលាស់ រីកចំរើនរឿយៗ ។

ជាពិសេសលោកអ្នកនាងមុខជាបានដល់នូវសុភមង្គលប្រចាំជីវិតផងក៏សឹងមាន សូមកត់សម្គាល់ចុះ ថាជោគជ័យសម្រាប់អស់លោកអ្នកក្នុងឆ្នាំនេះស្ថិតនៅខាងបូព៌ាទិស ។

ប្រុសអាយុ ១៣,២១,២៩,៣៧,៤៥, និង ៥០ ឆ្នាំ ។

ស្រីអាយុ ១៣,២១,២៩,៣៧,៤៥ និង ៥៣ ឆ្នាំ ។

២-លោកអ្នកនាងក្នុងឆ្នាំនេះ សូមកត់សម្គាល់ចុះថា បើមិនមានការជាចាំបាច់ មិនគួរធ្វើដំណើរទៅកាន់ទីឆ្ងាយនាទិសព្វសានញើកញាប់ពេកទេ ដោយផ្ទាល់ខ្លួនម្នាក់ឯង ក្រែងមានរឿងរ៉ាវបណ្តាលឡើងពីសត្រូវផ្ទុយភេទគ្នា វាចាប់ចោទដោយប្រការផ្សេងៗ ប្រសិនបើមើលទៅទិសនោះ ហើយជួនជាបានជួបប្រទះលាភមានជីវិតជើង២ នោះ គឺកុំគប្បីទទួល ឬអបអរសាទរត្រដក់ត្រសុំយកជាទីសង្ឃឹមឡើយ ម្យ៉ាងទៀតក្នុងឆ្នាំនេះ បើជាឱកាសគួរដល់ពេលវេលារៀបអាពាហ៍ពិពាហ៍ ប្រសិនបើមិនជាការចាំបាច់ទេ គប្បីសង្កេតពិនិត្យឱ្យម៉ត់ចត់ ។

ថាបើរឿងស្នេហា ដោយមិនពិចារណាហេតុផលឱ្យល្អិតល្អន់ទេ មុខតែមានវិបត្តិការណ៍កើតអមជាមួយគ្នា បើមិនឆាប់ក៏យូរមិនខាន ព្រោះរាសីអស់លោកអ្នកនាងក្នុងឆ្នាំនេះធ្លាក់ចុះក្នុងគំនរទុក្ខ ព្រោះស្នេហាជាទោស ។

ហេតុនេះ សូមតាំងចិត្តអំណត់ប្រុងស្មារតីចងចាំជានិច្ច តម្រង់មានះឱ្យបានរឹងជំហរ តទល់នឹងគ្រោះស្នេហ៍នាពេល នេះកុំឱ្យចូលមកជន្លឺបជន្លរ ឬទាញទាក់ស្មារតីអាត្មាបាន ។

ប្រុសអាយុ ១៤,២២,៣០,៣៨,៤៦ និង ៥៤ ឆ្នាំ

ស្រីអាយុ ១២,២០,២៨,៣៦,៤៤,៥២ និង ៦០ ឆ្នាំ ។

៣-អ្នកលោកអ្នកនាងក្នុងឆ្នាំនេះមុខជាមានភ័ព្វវាសនាបានជួបប្រទះនឹងលាភផលសមចិត្តប្រាថ្នាមិនខាន រាសីក្នុងឆ្នាំនេះអាចស្រូបបឺតយកលាភសក្ការៈដោយច្រើនៗ បានពីទិសឧត្តរ ចំពោះលាភលឿង និងលាភស តែគួរកត់សម្គាល់ចុះថាលាភផលទាំងឡាយដែលបានក្នុងឆ្នាំនេះលំបាកទុកដាក់ ឬផ្ញើឱ្យគត់គង់បន្តិច ព្រោះមានការដោយញាតិមិត្តត្រូវការភើចខ្ចី ឬសុំឱ្យជួយទំនុកបំរុងរឿយៗ បើមិនដូច្នេះទេក៏ត្រូវដូរដោះយកទ្រព្យរបស់ផ្សេងៗដទៃទៀតមកជំនួសវិញ ។

មួយវិញទៀត ច្រើនបានលាភគ្មានជីវិតច្រើនជាងមានជីវិត បណ្តាលលាភផលក្នុងពេលនេះ អាស្រ័យហេតុស្របនិងការប្រកបហើយនិងអំពើប្រព្រឹត្ត ព្យាយាមរបស់អាត្មា ព្រមជាមួយគ្នានិងវត្ថុធាតុដែលស្ថិតនៅក្បែកកិតជុំវិញខ្លួន ប្រសិនបើពោលពីទំហំលាភផលវិញ គ្រាន់តែឫក្សផ្កាយជតាចង្អុលលើ "មហទ្ធនោ" ផង ទើបលាភផលដ៏ស្តុកស្តម្ភបាន ។

តាមហេតុពិត ក្នុងឆ្នាំនេះ បើទេសកាលគួរដល់ការរៀបចំមង្គលការរបស់អស់លោកអ្នកកើតមានក្នុងពេលនេះផង ជាជោគជ័យប្រចាំគ្រួសារឥតមានអ្វីយកមកប្រដូចបានឡើយ ។

ប្រុសអាយុ ១៥,២៣,៣១,៣៩,៤៧ និង ៥៥ ឆ្នាំ ។

ស្រីអាយុ ១៩,២៧,៣៥,៤៣,៥១ និង ៥៩ ឆ្នាំ ។

៤-ក្នុងឆ្នាំនេះ លោកអ្នកនាងមុខតែបានទទួលការសៅហ្មងចិត្តច្រើនហើយ ជាការធម្មតាច្រើនមានសេចក្តីអួរអាប់ស្រពាប់ស្រពោនចិត្តញឹកញាប់បន្តិច សម្បូរការថ្នាំងថ្នាក់ជាច្រើន បើមិនក្នុងវង្សសង្គមគ្រួសារ ញាតិពន្ធ ឬញាតិសាខារមែងចោមរោមស្អប់ ឬទ្រុស្ត ពុំនោះសោតខ្លួនអាត្មាឯងច្រើនងប់ងុល វក់ទៅក្នុងវង់ល្បែងភ្នាល់ផ្សេងៗក៏សឹងមានការលើសខ្វះ ឬឆ្គាំឆ្គង ទោះជាចេតនាក្តី អចេតនាក្តី គឺចេះតែជួបប្រទះមិនសូវបានស្រាកស្រាន្ត ការបង្ករឿងទាំងខាងក្នុង និខាងក្រៅក៏ចេះតែផ្ទួចផ្តុំឡើងដរាប ចិត្តគំនិតច្រើនធ្លោយស័យស៊ុនណាស់ ពាក្យសម្តីនិយាយទៅកាន់អ្នកផងច្រើនតែជ្រុលមាត់ភ្លាត់ វាចាជាពិសេសត្រូវមានការខាតបង់ទ្រព្យធន ទោះតិច ឬច្រើនពុំលែងឡើយ ឬមួយមានវិវាទនិងសង្គមគ្រួសារ សឹងតែដល់នូវការវាយប្រហារគ្នាផងក៏សឹងមាន ពុំនោះមានឈ្លោះទាស់និងមនុស្សភេទដូចគ្នា រឿងនេះប្រសិនបើយកកម្លាំងគ្រឿងស្រវឹងជាជំនួយផង អ្នកម្ចាស់ជតាមុខតែលុះក្នុងរឿងរ៉ាវយ៉ាងធំលំបាក និងកែខ្លួនកើត ។

ហេតុនេះ សូមប្រយ័ត្នគ្រប់កិច្ចកលឱ្យជិតដល់ ទើបលោកអ្នកនាងបានជៀសចាកផុតពីគ្រោះកម្មប្រចាំអាយុក្នុង ឆ្នាំនេះបាន ។

ប្រុសអាយុ ១៦,២៤,៣២,៤០,៤៨ និង ៥៦ ឆ្នាំ ។

ស្រីអាយុ ១៨,២៦,៣៤,៤២, ៥០, និង ៥៨ ឆ្នាំ ។

៥-លោកអ្នកនាងក្នុងឆ្នាំនេះមុខតែបានទទួលការនឿយហត់ច្រើន សម្បូរទៅដោយសេចក្តីលំបាកចិត្តលំបាកកាយធ្វើការសារពើមានទំនាស់ច្រើន ការធ្វើដំណើរចេញទៅជិតឆ្ងាយ ច្រើនអសារឥតការ ជាពិសេសគ្រោះកម្មប្រចាំទិសបស្ចឹម បើលោកអ្នកនាងនៅតែផ្ទះច្រើនពេក ក៏ស្អុះស្អាប់សន្ធឹកសន្ធាប់ណាស់ដែរ បើមិនមានការចាំបាច់មិនគួរធ្វើដំណើរតាមជើងទឹកញឹកពេកទេ តាមពិតក្នុងឆ្នាំនេះ លោកអ្នកនាងគួរកត់សម្គាល់ឱ្យបាននូវលក្ខណៈជាការប្រចាំអាយុរបស់អាត្មា ចំពោះដំណើរការទៅកាន់ភូមិស្រុកឆ្ងាយ ទទួលបញ្ញើគេ ជួយឈឺឆ្អាលគេហួសកម្លាំង ធ្វើការងារដោយប្រើពេលវេលាច្រើនពេក ប្រកបកិច្ចការដោយឆ្លងកាត់ទឹកដូចឆ្លងបឹង ទន្លេជាដើម បង្ខំធ្វើការឱ្យហួសពីសមត្ថភាពអាត្មា ការដូចពោលនេះ សុទ្ធតែធ្លាក់ចុះទៅក្នុងហាយនៈជាប្រាកដ ។

ម្យ៉ាងទៀត គួរលោកអ្នកនាងប្រុងជើងការរកមធ្យោបាយលុបលាងនូវសេចក្តីអផ្សុកក្រវាយក្រវល់ចិត្តឱ្យមែន ទែនហើយគួរប្រើសេចក្តីពិចារណាស្ទង់មើលហេតុផលឱ្យបានជានិច្ចផង ទើបមានប្រសិទ្ធជោគបានល្អ ឬសម្រេចទៅបាន តាមតថាការ ។

ប្រុសអាយុ ១៧,២៥,៣៣,៤១,៤៩ និង ៥៧ ឆ្នាំ ។

ស្រីអាយុ ១៧,២៥,៣៣,៤១,៤៩ និង ៥៧ ឆ្នាំ ។

៦-លោកអ្នកនាងក្នុងឆ្នាំនេះ មានការបញ្ចេញញើស ចំណាយកម្លាំងច្រើនហើយ សូម្បីការងារដែលទាក់ទងនឹងប្រាក់មាសក៏មានភ្លាត់ខ្លះមិនលែងដែរ ហើយត្រូវរងគ្រោះចៃដន្យ ដូចជាប៉ះទង្គិច កោសមុតដល់សរីរាវយវៈផងក៏មាន

មានទ្រព្យឱ្យគេខ្ចីបុលចងការជឿបណ្តាក់មុខជាមានខូចខាត ឬកើតទោសព្រោះទ្រព្យឯង មិនគួរធ្វើដំណើរទៅទិសទីឆ្ងាយដាច់ស្រយាល ខាងលិច ឬខាងកើតទេ ដោយផ្ទាល់ខ្លួនម្នាក់ឯង គ្រោះភ័យនៅខាងមុខនឹងមានដល់ខ្លួនមិនខានឡើយ មួយវិញទៀតមិនគួរកកាប់រំលំឈើធំក្បែរភូមិផ្ទះ មិនគួរចូលព្រៃធំស្ងាត់ មិនគួរចូលព្រៃភ្នំធំ ព្រោះថារាសីរបស់អាត្មាក្នុងឆ្នាំនេះត្រូវឈើធំរលំសង្កត់ហើយ បើមិនដូច្នេះទេ បច្ចាមិត្តបំណងសាកល្បងកម្លាំង ឬក្រវែលលៃជើងភេលដើម្បីសម្រេចការព្យាបាទរបស់គេ ។

ប្រុសអាយុ ១៨,២៦,៣៤,៤២,៥០ និង ៥៨ ឆ្នាំ ។

ស្រីអាយុ ១៦,២៤,៣២,៤០,៤៨ និង ៥៦ ឆ្នាំ ។

៧-អស់លោកអ្នកនាងសូមជ្រាបថា ក្នុងឆ្នាំនេះជាភ័ព្វវាសនាល្អរបស់ខ្លួនវិលមកដល់ហើយ លាភជើង២ ជើង៤ មានជីវិតឥតជីវិត ត្រូវបានមកជាលទ្ធផលដល់លោកអ្នកនាងពិតមែន គូគ្រងប្រចាំជីវិតលោកអ្នកនាងមុខជាបានទទួលយកជាទ្រព្យព្រេងបូរាណ ការរបរសព្វបែបយ៉ាងនោះមានសភាពជាអ្វីក៏ដោយ ដែលលោកអ្នកបានព្យាយាម និងប្រព្រឹត្តសុទ្ធតែនាំមកនូវផលប្រយោជន៍ និងគុណបំណាច់យ៉ាងធំទូលាយ កិច្ចការផ្ទាល់ក្តី ប្រយោលក្តី ក្នុងការរាជការមុខតែបានទទួលកិត្តិយសឡើងតំណែងកាន់នាទីយ៉ាងខ្ពស់ ឧត្តមប្រយោជន៍ របស់លោកអ្នកនាងនៅត្រង់សេចក្តីសុខ រុងរឿង សម្បូរសប្បាយសុខដុមរមនាជួបជុំពង្សគ្រួសាររីករាយ ក្នុងឆ្នាំនេះហៅថា "មហាសុខ" ក្រៃលែង ។

ប្រុសអាយុ ១៩,២៧,៣៥,៤៣,៥១ និង ៥៩ ឆ្នាំ ។

ស្រីអាយុ ១៥,២៣,៣១,៣៩,៤៧ និង ៥៥ ឆ្នាំ ។

៨-លោកអ្នកនាង ក្នុងឆ្នាំដែលអាយុលោកអ្នកបានប៉ុណ្ណេះ ច្រើនទទួលការឈ្លានពាន និងប្រមាថមើលងាយពីគូសត្រូវរឿយៗ ពុំនោះសោតនឹងមានការប្រេះឆាបែកសាមគ្គីរវាងញាតិមិត្ត ឬអ្នករួមសង្គមកិច្ច កាលបើតាមហេតុពិត ការចងសម្ព័ន្ធមេត្រីក្នុងឆ្នាំនេះ នឹងមានការទង្គុតទង្គើ ឬប្រែក្លាយជាប្រការដទៃវិញ ហើយកិច្ចការដែលទាក់ទងនឹងសាហ៊ស គួរតែប្រយ័ត្នឱ្យមែនទែន កុំសាកល្បង កុំជន្លរ ព្រោះរាសីរបស់លោកអ្នកនាងក្នុងឆ្នាំនេះធ្លាក់ចុះក្នុងគំនរភ័យនៃលោហិតស្រក់ ដាក់កាយម្យ៉ាងទៀត បើធ្វើដំណើរចូលព្រៃជ្រៅ តោងប្រយ័ត្នម្រឹកសាហាវវាបៀតបៀន មិនតែប៉ុណ្ណោះទេតោងប្រើ ស្មារតីឱ្យខ្ជាប់ខ្ជួនផងមិនគួរបណ្តែតបណ្តោយ ទោះពេលណាក៏ដូចជាពេលណា ទ្រព្យសម្បត្តិច្រើនជ្រុះបាត់ឬបាក់បែក ចំណែកសេចក្តីទុកទោមនស្សមានប្រចាំអាយុ មានជាទេ្វភាគអាគ្នេយ៍ទិស ។

បើតាមគោលការណ៍របស់ហោរានិយម ក្នុងពេលមានគ្រោះចរប្រចាំអាយុវិលមកជួប ត្រូវតែរៀបចំពិធីរំដោះដោយនិមន្តព្រះសង្ឃសូត្រទិព្វនិមន្ត ទើបជាកិច្ចរួចជោគគ្រោះបានគ្រប់យ៉ាង ។

.................................................

## រូបភាពទំព័រ (១៤៨)

កាលបើលោកអ្នកនាងចង់រើសគូគ្រងប្រចាំជីវិតរៀងខ្លួន ដើម្បីរក្សាគ្នាឱ្យបានសុខសម្បូរ នៅរួមរស់ជាមួយគ្នាបានយឺនយូរប្រកបទៅដោយវឌ្ឍនភាព មានសុភមង្គលព្រមទៅដោយសុភវិនិច្ឆ័យ រីករាយសប្បាយរួមសាមគ្គីដល់គ្នានិងគ្នាដរាបដល់អវសាននោះ មុននឹងចូលចងសម្ព័ន្ធមេត្រីស្តីដណ្តឹង សូមសង្កេតពិនិត្យមើលរកហេតុបច្ច័យ និងលក្ខណៈរកគូសម្ព័ន្ធ

ឱ្យដឹងគ្រប់សព្វ ដូចជា "សម្ព័ន្ធថ្ងៃកំណើត ខែកំណើត"ជាដើម ឱ្យដឹងហើយប្រមើលធៀបគ្នាវិញបញ្ចូលធ្លុងតែមួយ បើ ឃើញថាមិនស្របធ្លុងខ្វាញ់ស្និទ្ធល្អទេ នោះគប្បីលៃរេគិតតទៅទៀត ។

តែបើតាមប្រវេណីបុព្វបុរសយើង "ជំនាន់បុរាណ"និយមការជ្រើសរើសផ្សំគូស្រករ រមែងមានការសង្កេតរកហេតុផលទាំងសងខាង លុះត្រាតែបានផលល្អស្របគ្នា ទើបបានយល់ព្រមឱ្យរៀបសម្រេច ផ្សំជាស្វាមី ភរិយា ដោយបុព្វបុរស យើងយល់ថាការចងសម្ព័ន្ធគ្រួសារ គឺចំណងសម្រាប់អាយុជីវិតវង្សត្រកូល និងជាពលិកាដល់ប្រទេសជាតិផង ។

...............................